**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៣៦.អនក្រ.បក

**អនុក្រឹត្យ**
**ស្តីពី**

**ការកាត់ផ្ទៃដីទំហំ ៣ ៥០០ ហិកតា ចេញពីរបៀងអភិរក្សជីវៈចម្រុះនៃប្រព័ន្ធតំបន់ការពារធម្មជាតិ និងធ្វើអនុបយោគពីដីសាធារណៈរបស់រដ្ឋមកជាដីឯកជនរបស់រដ្ឋ សម្រាប់អនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រគ្មានដីពិតប្រាកដ ស្ថិតនៅភូមិ៣ ឃុំត្រពាំងក្រហម ស្រុកកូនមុំ ខេត្តរតនគិរី**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា១.-**

កាត់ផ្ទៃដីទំហំ ៣ ៥០០ ហិកតា ចេញពីរបៀងអភិរក្សជីវៈចម្រុះនៃប្រព័ន្ធតំបន់ការពារធម្មជាតិ និងធ្វើអនុបយោគពីដីសាធារណៈរបស់រដ្ឋមកជាដីឯកជនរបស់រដ្ឋ សម្រាប់អនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រគ្មានដីពិតប្រាកដ ក្រោមគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដំណាក់កាលទី៣ (LASED III) ស្ថិតនៅភូមិ៣ ឃុំត្រពាំងក្រហម ស្រុកកូនមុំ ខេត្តរតនគិរី តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 ដូចមានផែនទីបង្ហាញទីតាំងដី និងតារាងនិយាមកាជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ។

**មាត្រា២.-**

ប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ខាងលើ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តរតនគិរី ដើម្បីធ្វើការគ្រប់គ្រង និងចាត់ចែងស្របតាមនីតិវិធីជាធរមាន។

**មាត្រា៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តរតនគិរី ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១២ កើត ខែ ចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ផែនទី និងតារាងនិយាមការឧបសម្ព័ន្ធអនុក្រឹត្យលេខ.៧៦.អនក្រ.បក. ចុះថ្ងៃទី....១៣.... ខែ....មេសា...... ឆ្នាំ២០២២




តារាងចំណុចនិយាមការ ដីស្នើសុំធ្វើអនុផលយោគ សម្រាប់សម្បទានដីសង្គមកិច្ច សម្រាប់ប្រជាពលរដ្ឋក្រីក្រ

ស្ថិតនៅភូមិ៣ ឃុំត្រពាំងក្រហម ស្រុកកូនមុំ ខេត្តរតនគិរី

Projection UTM, Zone 48N,WGS1984

| Point_ID | Northing(m) | Easting(m) | Point_ID | Northing(m) | Easting(m) | Point_ID | Northing(m) | Easting(m) |
|---|---|---|---|---|---|---|---|---|
| 1 | 1512038 | 667844 | 31 | 1509291 | 674082 | 61 | 1510045 | 671489 |
| 2 | 1512032 | 668015 | 32 | 1509338 | 674095 | 62 | 1509999 | 671443 |
| 3 | 1512824 | 669227 | 33 | 1509397 | 674062 | 63 | 1509918 | 671412 |
| 4 | 1513024 | 669558 | 34 | 1509463 | 673943 | 64 | 1510316 | 670865 |
| 5 | 1513124 | 669879 | 35 | 1509470 | 673851 | 65 | 1510315 | 669968 |
| 6 | 1513175 | 670280 | 36 | 1509503 | 673804 | 66 | 1509873 | 669971 |
| 7 | 1513175 | 670681 | 37 | 1509602 | 673745 | 67 | 1509888 | 669699 |
| 8 | 1513134 | 671021 | 38 | 1509675 | 673745 | 68 | 1509893 | 669603 |
| 9 | 1513175 | 671572 | 39 | 1509735 | 673679 | 69 | 1509988 | 667833 |
| 10 | 1513575 | 671753 | 40 | 1509754 | 673553 | 70 | 1513375 | 674552 |
| 11 | 1513666 | 671843 | 41 | 1509688 | 673533 | 71 | 1513383 | 674885 |
| 12 | 1513726 | 672184 | 42 | 1509569 | 673467 | 72 | 1513153 | 675012 |
| 13 | 1513806 | 672464 | 43 | 1509490 | 673407 | 73 | 1512804 | 674957 |
| 14 | 1514066 | 672966 | 44 | 1509496 | 673321 | 74 | 1512835 | 674806 |
| 15 | 1514147 | 673076 | 45 | 1509609 | 673288 | 75 | 1513026 | 674623 |
| 16 | 1514227 | 673296 | 46 | 1509655 | 673196 | 76 | 1513232 | 674552 |
| 17 | 1514282 | 673371 | 47 | 1509662 | 673057 | 77 | 1512290 | 671564 |
| 18 | 1514243 | 677075 | 48 | 1509721 | 672958 | 78 | 1512475 | 670790 |
| 19 | 1510652 | 677080 | 49 | 1509754 | 672865 | 79 | 1512549 | 670771 |
| 20 | 1510646 | 676862 | 50 | 1509662 | 672720 | 80 | 1512638 | 670784 |
| 21 | 1510030 | 676690 | 51 | 1509701 | 672495 | 81 | 1512757 | 670962 |
| 22 | 1509293 | 675573 | 52 | 1509781 | 672389 | 82 | 1512932 | 671067 |
| 23 | 1508974 | 675514 | 53 | 1509801 | 672250 | 83 | 1513086 | 671035 |
| 24 | 1508835 | 674883 | 54 | 1509887 | 672217 | 84 | 1513104 | 671099 |
| 25 | 1509021 | 673944 | 55 | 1510045 | 672045 | 85 | 1512966 | 671179 |
| 26 | 1509139 | 673950 | 56 | 1510078 | 671946 | 86 | 1512838 | 671430 |
| 27 | 1509159 | 673818 | 57 | 1510151 | 671985 | 87 | 1512723 | 671498 |
| 28 | 1509212 | 673818 | 58 | 1510310 | 671939 | 88 | 1512611 | 671466 |
| 29 | 1509245 | 673890 | 59 | 1510310 | 671853 | 89 | 1512407 | 671508 |
| 30 | 1509258 | 674003 | 60 | 1510145 | 671701 | | | |

ផែនទីបង្ហាញទីតាំងដីទំហំ ៣៥០០ ហិកតា ដែលស្នើកាត់ចេញពីតំបន់របៀងអភិរក្សជីវៈចម្រុះនៃប្រព័ន្ធតំបន់ការពារធម្មជាតិ
និងធ្វើអនុបយោគពីដីសាធារណៈរបស់រដ្ឋមកជាដីឯកជនរបស់រដ្ឋ សម្រាប់កម្មវិធីសម្បទានដីសង្គមកិច្ច ជូនប្រជាពលរដ្ឋក្រីក្រដែលគ្មានដីពិតប្រាកដ
ស្ថិតនៅភូមិ៣ ឃុំត្រពាំងក្រហម ស្រុកកូនមុំ ខេត្តរតនគិរី




តារាងចំណុចនិយាមកា ដីស្នើសុំធ្វើអនុបយោគ សម្រាប់សម្បទានដីសង្គមកិច្ច សម្រាប់ប្រជាពលរដ្ឋក្រីក្រ

ស្ថិតនៅភូមិ៣ ឃុំត្រពាំងក្រហម ស្រុកកូនមុំ ខេត្តរតនគិរី

Projection UTM, Zone 48N,WGS1984

| Point_ID | Northing(m) | Easting(m) | Point_ID | Northing(m) | Easting(m) | Point_ID | Northing(m) | Easting(m) |
|---|---|---|---|---|---|---|---|---|
| 1 | 1512038 | 667844 | 31 | 1509291 | 674082 | 61 | 1510045 | 671489 |
| 2 | 1512032 | 668015 | 32 | 1509338 | 674095 | 62 | 1509999 | 671443 |
| 3 | 1512824 | 669227 | 33 | 1509397 | 674062 | 63 | 1509918 | 671412 |
| 4 | 1513024 | 669558 | 34 | 1509463 | 673943 | 64 | 1510316 | 670865 |
| 5 | 1513124 | 669879 | 35 | 1509470 | 673851 | 65 | 1510315 | 669968 |
| 6 | 1513175 | 670280 | 36 | 1509503 | 673804 | 66 | 1509873 | 669971 |
| 7 | 1513175 | 670681 | 37 | 1509602 | 673745 | 67 | 1509888 | 669699 |
| 8 | 1513134 | 671021 | 38 | 1509675 | 673745 | 68 | 1509893 | 669603 |
| 9 | 1513175 | 671572 | 39 | 1509735 | 673679 | 69 | 1509988 | 667833 |
| 10 | 1513575 | 671753 | 40 | 1509754 | 673553 | 70 | 1513375 | 674552 |
| 11 | 1513666 | 671843 | 41 | 1509688 | 673533 | 71 | 1513383 | 674885 |
| 12 | 1513726 | 672184 | 42 | 1509569 | 673467 | 72 | 1513153 | 675012 |
| 13 | 1513806 | 672464 | 43 | 1509490 | 673407 | 73 | 1512804 | 674957 |
| 14 | 1514066 | 672966 | 44 | 1509496 | 673321 | 74 | 1512835 | 674806 |
| 15 | 1514147 | 673076 | 45 | 1509609 | 673288 | 75 | 1513026 | 674623 |
| 16 | 1514227 | 673296 | 46 | 1509655 | 673196 | 76 | 1513232 | 674552 |
| 17 | 1514282 | 673371 | 47 | 1509662 | 673057 | 77 | 1512290 | 671564 |
| 18 | 1514243 | 677075 | 48 | 1509721 | 672958 | 78 | 1512475 | 670790 |
| 19 | 1510652 | 677080 | 49 | 1509754 | 672865 | 79 | 1512549 | 670771 |
| 20 | 1510646 | 676862 | 50 | 1509662 | 672720 | 80 | 1512638 | 670784 |
| 21 | 1510030 | 676690 | 51 | 1509701 | 672495 | 81 | 1512757 | 670962 |
| 22 | 1509293 | 675573 | 52 | 1509781 | 672389 | 82 | 1512932 | 671067 |
| 23 | 1508974 | 675514 | 53 | 1509801 | 672250 | 83 | 1513086 | 671035 |
| 24 | 1508835 | 674883 | 54 | 1509887 | 672217 | 84 | 1513104 | 671099 |
| 25 | 1509021 | 673944 | 55 | 1510045 | 672045 | 85 | 1512966 | 671179 |
| 26 | 1509139 | 673950 | 56 | 1510078 | 671946 | 86 | 1512838 | 671430 |
| 27 | 1509159 | 673818 | 57 | 1510151 | 671985 | 87 | 1512723 | 671498 |
| 28 | 1509212 | 673818 | 58 | 1510310 | 671939 | 88 | 1512611 | 671466 |
| 29 | 1509245 | 673890 | 59 | 1510310 | 671853 | 89 | 1512407 | 671508 |
| 30 | 1509258 | 674003 | 60 | 1510145 | 671701 | | | |